ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ: ធ៥-០១៨-៣០៤ ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រគំរូថ្មី
# របស់ធនាគារជាតិនៃកម្ពុជា

*********

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤១៧ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាជាថ្មី មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៥/០៣០ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់
- យោងប្រកាសលេខ ធ៩-០៨-១៨៦ប្រក ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីមូលប្បទានប័ត្រស្តង់ដារ
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានបច្ចេកទេស ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨

## សម្រេច

**ប្រការ ១**:

ប្រកាសនេះមានគោលបំណងដាក់ឱ្យប្រើប្រាស់មូលប្បទានប័ត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជា ចំនួន ២(ពីរ) ប្រភេទគឺមូលប្បទានប័ត្រចារឹកជាប្រាក់រៀល និងមូលប្បទានប័ត្រចារឹកជាប្រាក់ដុល្លារអាមេរិក ដើម្បីបង្កើនគុណភាព ប្រសិទ្ធិភាព និងសុវត្ថិភាពនៃការទូទាត់តាមរយៈមូលប្បទានប័ត្រ ។

**ប្រការ ២**:

ប្រកាសនេះមានគោលដៅកំណត់លក្ខណៈសម្គាល់នៃមូលប្បទានប័ត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជាដែលនឹងត្រូវជំនួសមូលប្បទានប័ត្រដែលកំពុងប្រើបច្ចុប្បន្ន ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

**ប្រការ ៣:**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអតិថិជនដែលមានគណនីចរន្តនៅធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៤:**

មូលប្បទានប័ត្រគំរូថ្មីនេះ មានលក្ខណៈសម្គាល់ដូចតទៅ៖

ក-លក្ខណៈទូទៅ

១-ទំហំមូលប្បទានប័ត្រ: បណ្ដោយ ១៨០មម ទទឹង ៩០មម

២-ពណ៌នៃមូលប្បទានប័ត្រ

២.១. ប្រភេទប្រាក់រៀល

- ផ្ទៃខាងឆ្វេង: ពណ៌ទង់ដែងស្រាល និងផ្ទៃខាងស្ដាំ: ពណ៌មរកតស្រាល
- ទីតាំងសម្រាប់ចុះចំនួនប្រាក់: ពណ៌លឿង
- ទីតាំងសម្រាប់ចុះហត្ថលេខាបហារ៉ក: ពណ៌លឿងស្រាល

២.២. ប្រភេទប្រាក់ដុល្លារអាមេរិក

- ផ្ទៃខាងឆ្វេង: ពណ៌មរកតស្រាល និងផ្ទៃខាងស្ដាំ: ពណ៌ទង់ដែងស្រាល
- ទីតាំងសម្រាប់ចុះចំនួនប្រាក់: ពណ៌ផ្ទៃមេឃ
- ទីតាំងសម្រាប់ចុះហត្ថលេខាបហារ៉ក: ពណ៌ផ្ទៃមេឃស្រាល

៣-មូលប្បទានប័ត្រគំរូថ្មីរបស់ធនាគារជាតិនៃកម្ពុជា ស្នាក់ការកណ្ដាលនិងសាខា គឺមានលក្ខណៈដូចគ្នាទាំងស្រុង លើកលែងតែអាសយដ្ឋានប៉ុណ្ណោះ ។

ខ-លក្ខណៈពិសេស

សន្លឹកមូលប្បទានប័ត្រ ត្រូវបានបោះពុម្ពដោយក្រដាសពិសេស និងមានលក្ខណៈពិសេសដូចខាងក្រោម៖

១. ផ្ទៃក្រដាសមានរូបបណ្ដុះពង្រាយសព្វ និងមានបង្កប់ក្នុងក្រដាសនូវកំណាត់ខ្សែសុវត្ថិភាពឆ្មារៗ មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពន្លឺពណ៌លឿង ក្រហម និងពណ៌ផ្ទៃមេឃ ។

២. ផ្នែកកន្ទុយសន្លឹកមានគំនូសបន្ទាត់ពិសេសមិនរៀបរយ និងមានកម្រាស់បន្ទាត់ប្រែប្រួលមិនស្មើគ្នា ។

៣. ផ្នែកកណ្ដាលមានរូបឡូហ្គោធនាគារជាតិនៃកម្ពុជាព្រាលៗ ផ្គុំដោយគំនូសបន្ទាត់ពិសេសមិនរៀបរយ ដែលមានកម្រាស់ប្រែប្រួលមិនស្មើគ្នា ។

៤. ផ្ទៃជុំវិញរូបឡូហ្គោមានរូបភាពផ្ទៃលំអ បង្កើតដោយគំនូសបន្ទាត់ពិសេសមិនរៀបរយ ។

៥. ផ្ទៃកណ្ដាលមានពណ៌ឥន្ទធនូពីរពណ៌ ក្នុងនោះពណ៌មួយមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌លឿង ។

៦. លេខមាលាពណ៌ក្រហម មានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជាពណ៌ទឹកក្រូច ។

៧. ចំណុចខាងលើទីតាំងសម្រាប់ចុះចំនួនប្រាក់ត្រូវបានបោះពុម្ពដោយទឹកខ្មៅអទិស្សមានមានចំណាំងពន្លឺក្រោមរស្មីពណ៌ស្វាយចេញជារូបពណ៌លឿង នៃឡូហ្គោធនាគារជាតិនៃកម្ពុជា អក្សរ "CHECK NBC" និងផ្ទៃពិសេសប្រឆាំងការកោសលុប ។

៨. ទីតាំងសម្រាប់ចុះកាលបរិច្ឆេទដែលមានអក្សរនិងស៊ុមព័ទ្ធជុំវិញ មើលឃើញព្រាលៗ បង្កើតឡើងដោយកំណាត់បន្ទាត់ខ្លីៗ ។

៩. ទីតាំងសម្រាប់ចុះហត្ថលេខាបហារ័កមានផ្ទៃបោះពុម្ពលំអ បង្កើតឡើងដោយគំនូសបន្ទាត់ពិសេសមិនរៀបរយ និងមានកម្រាស់បន្ទាត់ផ្សេងៗគ្នា ។

១០. នៅផ្នែកខាងឆ្វេងជ្រុងលើមានរូបឡូហ្គោធនាគារជាតិនៃកម្ពុជា បោះពុម្ពដោយទឹកខ្មៅមានធាតុលោហៈ ពណ៌ប្រាក់ និងពណ៌ទង់ដែង ។

១១. អក្សរដ៏តូចល្អិត "NATIONAL BANK OF CAMBODIA" ផ្គុំបង្កើតជាបន្ទាត់ឆ្នូរៗ អាចមើលឃើញច្បាស់ដោយកែវពង្រីក ។

១២. នៅផ្នែកខាងក្រោមមានរូបភាពក្បាច់លំអ បោះពុម្ពដោយគំនូសបន្ទាត់ពិសេសប្រណិត និងមានការប្តូរពីពណ៌មួយទៅពណ៌មួយទៀតដោយរលូន ។

**ប្រការ ៥:**

អតិថិជនរបស់ធនាគារជាតិនៃកម្ពុជា ត្រូវយកមូលប្បទានប័ត្រគំរូចាស់មកប្តូរយកមូលប្បទានប័ត្រគំរូថ្មីយ៉ាងយូរបំផុតត្រឹមរយៈពេល ១ខែ បន្ទាប់ពីថ្ងៃចុះហត្ថលេខានៃប្រកាសនេះ ។

**ប្រការ ៦:**

រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧:**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និងគ្រប់សាខាធនាគារជាតិនៃកម្ពុជា អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលនៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តយ៉ាងម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨:**

ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃព្រហ ២ រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ កញ្ញា ឆ្នាំ២០១៨

**ទេសាភិបាល**

ជា_ចាន់តូ

**កន្លែងទទួល**

-ប្រការ ៧ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

**ចម្លងជូន**

-នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"